ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

លេខ : ✓ មស.

**សារលិខិតអបអរសាទរ**

**ខួបលើកទី៤៣ នៃទិវាជ័យជម្នះ ៧មករា**

**សូមគោរពជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

**សម្តេចអគ្គមហាសេនាបតីតេជោ ជាទីគោរពដ៏ខ្ពង់ខ្ពស់**

យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ មានសេចក្តីសោមនស្សរីករាយឥតឧបមា ចំពោះខួបលើកទី៤៣ នៃទិវាជ័យជម្នះ ៧មករា ដែលជាថ្ងៃរំដោះប្រជាជនកម្ពុជា ឱ្យរួចផុតពីការកាប់សម្លាប់ក្នុងមហាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយបានបើកឡើងនូវសករាជថ្មីនៃកម្ពុជា។

ក្នុងឱកាសដ៏នក្ខត្តឫក្សនេះ យើងខ្ញុំសូមសម្តែងនូវសេចក្តីគោរពដឹងគុណដ៏ស្មោះស្ម័គ្រ ចំពោះគុំរូវីរភាពដ៏ឆ្នើមរបស់ **សម្តេចតេជោ** ដែលបានបំពេញបេសកកម្មជាប្រវត្តិសាស្ត្រប្រកបដោយជោគជ័យដ៏ត្រចះត្រចង់ក្នុងការរំដោះប្រទេសជាតិ ស្វែងរកសន្តិភាព បង្រួបបង្រួមជាតិ កសាង និងអភិវឌ្ឍន៍ប្រទេសជាតិឱ្យមានការរីកចម្រើនជាលំដាប់។ រាជរដ្ឋាភិបាលក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោ** បានធ្វើឱ្យព្រះរាជាណាចក្រកម្ពុជាសម្រេចនូវសមិទ្ធផលលើគ្រប់វិស័យដ៏វិសេសវិសាលជាបន្តបន្ទាប់ ដោយថែរក្សាបាននូវសុខសន្តិភាព អធិបតេយ្យភាព បូរណភាពទឹកដីដ៏រឹងមាំ ឯកភាពជាតិ ស្ថិរភាពជាតិ និងការរីកចម្រើនជឿនលឿនទៅមុខ។

យើងខ្ញុំសូមបួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិក្នុងលោក សូមប្រោសប្រទានជូន **សម្តេចអគ្គមហាសេនាបតីតេជោ និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រី** សូមមានសុខភាពល្អបរិបូរណ៍ និងពុទ្ធពរដ៏មហាប្រសើរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅ និងគារវកិច្ចខ្ពង់ខ្ពស់បំផុតពីយើងខ្ញុំ។

ថ្ងៃ ពុធ ៣ កើត ខែ បុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែមករា ឆ្នាំ២០២២

**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ**

**រដ្ឋមន្ត្រី**

**ហ៊ុំ សុខា**

ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh